អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ របៀបចំរើនសមថកម្មដ្ឋាន (ត)

website ៖ www.hoksavann.org

ថ្ងៃទី២៣ សីហា ២០០៨



មុននឹងចំរើនសមថកម្មដ្ឋានទាំង៤០ កម្មដ្ឋានណាមួយត្រូវលះបង់ហារិពោធ ការជាប់ជំពាក់កិច្ចការអ្វីមួយ ឬត្រូវធ្វើបង្ហើយ ដោយហោចណាស់ក៏កុំឲ្យជាប់ជំពាក់ក្នុងពេលចំរើនធម៌ ។ ត្រូវនមស្សការព្រះរតនត្រ័យដោយសេចក្ដីសង្ខេប ។ ត្រូវពិចារណាទោសរបស់កាមគុណទាំង៥ គឺរូប សម្លេង ក្លិន រស និងសម្ផស្ស ដើម្បីការពារកុំឲ្យចិត្តនឹកទៅរកកាមគុណទាំង៥នេះនៅពេលចំរើនធម៌ ។ ត្រូវផ្សាយមេត្តាចិត្ត ដើម្បីការពារកុំឲ្យចិត្តគិតប្រទូស្សនៅពេលចំរើនធម៌ ។ ត្រូវជំរះសីលរបស់ខ្លួនឲ្យបរិសុទ្ធតាមប្រភេទសីលរបស់បព្វជិតនិងគ្រហស្ថ ។ ត្រូវពិចារណាបដិបទា គឺផ្លូវប្រតិបត្តិដោយពិចារណាថា ផ្លូវប្រតិបត្តិនេះហើយជាដំណើររបស់ព្រះអរិយបុគ្គលដែលលោកប្រតិបត្តិដើម្បីរំលត់ទុក្ខពោលគឺព្រះនិព្វាន ។ ការពិចារណាដូច្នេះ ដើម្បីឲ្យមានសេចក្ដីសង្ឃឹមក្នុងការប្រតិបត្តិនេះ ។ ការពិចារណានេះត្រូវអនុវត្តក្នុងរយៈពេលខ្លី ដើម្បីរំដោះផ្លូវចិត្តមុននឹងលើកធម៌យកមកចំរើន ។ អ្នកទើបហាត់ចំរើនធម៌ជាដំបូង គួររកទីស្ងាត់ ប៉ុន្តែអ្នកដែលធ្លាប់បានចំរើនថ្លឹកហើយ ទោះទៅចំរើនក្នុងទីណាក៏បាន ប្រៀបដូចសត្វគោដែលគេបង្ហាត់បានបទហើយ ទោះបីគេដឹកវានៅក្នុងចំណោមមនុស្សច្រើន ក៏វាមិនផ្អើលទេ ។ ការចំរើនធម៌អាចធ្វើបានគ្រប់ឥរិយាបថទាំង៤ ។ បើអង្គុយពិចារណាមានពេលខ្លះចិត្តអាចរាយមាយមិនស្ងប់ ដូច្នេះគួរដើរចង្ក្រម ព្រោះការដើរចង្ក្រមជាវិធីមួយធ្វើចិត្តឲ្យឆាប់ស្ងប់ ទើបត្រឡប់មកអង្គុយវិញ ។

ការដើរចង្ក្រមអាចអនុវត្តជា២បែប គឺការដើរចង្ក្រមយឺតៗ និងការដើរចង្ក្រមតាមដំណើរធម្មតា គឺចង្ក្រមលឿន ។ ការដើរចង្ក្រម គ្រាន់តែកំណត់ឆ្វេងស្តាំ គឺបើបោះជើងឆ្វេងកំណត់ថាឆ្វេង បោះជើងស្តាំ កំណត់ថាស្តាំ វិធីនេះគឺការប្រមូលចិត្តឲ្យឆាប់ស្ងប់នីវរណធម៌ ។

ដូចបានពោលមកហើយ ការចំរើនឲ្យកើតសមាធិចិត្ត គឺដើម្បីឲ្យស្ងប់នូវនីវរណធម៌ទាំង៥ ដែលបាលីពោលថា ចេតោវិមុត្តិ ប្រែថាការរួចចាកនីវរណធម៌តាំង៥ ដោយអំណាចសមាធិចិត្ត ។ ចំណែកវិបស្សនាមានទំនាក់ទំនងជាមួយសមាធិ ព្រោះបើចិត្តកើតមាមសមាធិស្ងប់នីវរណធម៌ទាំង៥ហើយ ចិត្តនេះមានសមត្ថភាពពិចារណានូវខន្ធ៥ឲ្យឃើញអនិច្ចំ ទុក្ខំ និងអនត្តា ដែលជាតួវិបស្សនានេះឯង ។ អានិសង្សនៃសមាធិមាន៥យ៉ាងគឺ ៖

១- មានកិរិយានៅជាសុខក្នុងបច្ចុប្បន្ន ដោយសារការស្ងប់ផ្លូវចិត្ត ព្រោះនីវរណធម៌ទាំង៥រាំងផ្លូវចិត្តមិនឲ្យស្ងប់ ។

២- ជាបទដ្ឋាននៃវិបស្សនា ព្រោះបើសមាធិចិត្តកើតឡើងហើយ អាចចំរើនឲ្យកើតវិបស្សនាបាន ។

៣- មានអភិញ្ញាជាអានិសង្ស គឺបើបុគ្គលចំរើនឲ្យកើតរហូតដល់សមាបត្តិ៨ អាចហ្វឹកហាត់ឲ្យកើតអភិញ្ញាបាន ។

៤- បើមិនទាន់បានសំរេចព្រះនិព្វានទេ បើចំរើនឈានឲ្យកើតឡើង អាចកើតក្នុងព្រហ្មលោក បើចំរើនឲ្យកើតឧបចារសមាធិ អាចកើតក្នុងសុគតិភព គឺមនុស្សនិងទេវតា ។

៥- ចំពោះព្រះអរិយបុគ្គលថ្នាក់អនាគាមី និងព្រះអរហន្ត ដែលជាបដិសម្ភិទាញាណ អាចចូលនិរោធសមាបត្តិ នៅជាសុខក្នុងបច្ចុប្បន្នបាន៧ថ្ងៃ ដោយសារការមានអប្បនាសមាធិរហូតសមាបត្តិ៨ គឺរូបជ្ឈាន៤ និងអរូបជ្ឈាន៤ ។

នេះជាអានិសង្សនៃឧបចារសមាធិនិងអប្បនាសមាធិ បើពោលឲ្យដាច់ដោយឡែកពីគ្នា រវាងសីល សមាធិ និងបញ្ញា ។ បើពោលឲ្យមានទំនាក់ទំនងគ្នា គឺត្រៃសិក្ខាទាំងបីនេះ ត្រូវប្រតិបត្តិទាំងបីរួមគ្នា ដើម្បីរំដោះទុក្ខសម្រេចព្រះនិព្វានជាពិសេសសមាធិជាបទដ្ឋាន គឺជាហេតុនៃវិបស្សនា ។ ដូចបានពោលមកហើ-យ សីលដើម្បីលះទោសគ្រោតគ្រាត ដែលប្រព្រឹត្តទៅតាមផ្លូវកាយនិងវាចា ស

មាធិលះទោសយ៉ាងកណ្ដាល គឺនីវរណធម៌ទាំង៥ ឯបញ្ញាឃើញត្រៃលក្ខណធម៌ក្នុងខន្ធ៥លះកិលេសយ៉ាងល្អិត ។ ដូចនេះ កុំយល់ថា ធ្វើសមាធិដើម្បីទៅមើលស្ថានទេវតា ស្ថាននរក ទៅមើលភ្នំព្រះសុមេរុ ឬចង់ដឹងថាខ្លួនស្លាប់ទៅតើទៅកើតក្នុងទីណា ។ របស់ទាំងនេះអាចឃើញ បើគេចំរើនឲ្យកើតអភិញ្ញាផ្នែកទិព្វចក្ខុ ប៉ុន្តែពុំមែនជាបំណងពិតរបស់ព្រះពុទ្ធសាសនាឡើយ ។ បំណងពិត គឺការរំដោះទុក្ខផ្នែកវិបស្សនាវិជ្ជា រំដោះខ្លួនចេញពីការកើតចាស់ឈឺស្លាប់ក្នុងវដ្ដសង្សារ ។ ចំពោះអ្នកមានឧបនិស្ស័យចាស់ក្លា គេចាប់ចំរើនវិបស្សនាតែម្ដងដោយមានសីលនិងសមាធិនៅជាមួយហើយ ។៚

❇ ❇

❇